

# ខ្មែរប្រឹងងើបឡើងវិញនៅសតវត្សទី១៦

(ដោយបណ្ឌិត អាំង ជូលាន )

បើយកវិស័យនយោបាយ, សេដ្ឋកិច្ច និងយោធាមកពោល ឃើញថា «សម័យកណ្ដាល» នៃប្រទេសកម្ពុជា (ស.វ. ទី១៤ ដល់ដើម១៩) មានការស្រុតចុះជាទូទៅ ជួនស្រាល ជួនធ្ងន់ធ្ងរ ពុំអាចប្រៀបទៅសម័យបុរាណ (ស.វ. ទី៦ ដល់ដើម១៤) ដែលច្រើនតែថ្កុំថ្កើងនោះបានឡើយ។ ខ្ញុំពុំលើកវិស័យស្ថាបត្យកម្មនិងសិល្បៈឈើ, តម្បាញគ្រប់បែបយ៉ាង, អក្សរសាស្ត្រ, ទំនៀមទម្លាប់, សីលធម៌ជាដើមនោះមកពោលទេ ដ្បិតវិស័យទាំងអស់នេះហាក់គ្មានចុះស្រុតឱនថយអ្វីឡើយ។ តែវិស័យនយោបាយ ... ដូចពោលខាងលើឃើញថាមានការប្រែប្រួលខ្លាំងនៅស.វ.ទី១៥ ហើយការក្រលាប់ចាក់ធំជាងគេ គឺរាជធានីអង្គរត្រូវរលំនៅ រវាងគ.ស.១៤៣២។ ការចុះដុនដាបក្នុងវិស័យដដែលនេះ ឃើញថាធ្ងន់ធ្ងរណាស់ដែរនៅស.វ.ទី១៨ ព្រមទាំងផ្នែកដំបូងនៃស.វ.ទី១៩។ បើនៅស.វ.ទី ១៧ហាក់ដូចជានៅទ្រឹង ចំណែកឯស.វ.ទី១៦ បើដកយកប៉ែកខាងដើមនិងប៉ែកខាងចុងចេញ ឃើញថាខុសគេ។ ខ្មែរមួយរយៈនោះងើបឡើងបានមួយគ្រា។ ព្រះបាទអង្គច័ន្ទទី១ (ព្រះរាជពង្សាវតាហៅថាព្រះបាទច័ន្ទរាជា) ជាអ្នកផ្ដួចផ្ដើមចលនានេះ។ ទឹកដីខ្វះដែលបាត់បង់ទៅកាលពីរាជ្យមុនៗ ដូចជាតំបន់នគររាជ ត្រូវបានព្រះអង្គវាយដណ្ដើមយកមកវិញ។ ថ្វីដ្បិតែរាជធានីពេលនោះនៅបន្ទាយលង្វែក ព្រះបាទច័ន្ទរាជាទៅគង់នៅអង្គរវិញមួយរយៈយូរ ដើម្បីរៀបចំបុរាណដ្ឋានខ្វះៗឱ្យបានសមរម្យឡើងវិញ។ សមិទ្ធិផលដ៏សំខាន់មួយ គឺការឆ្លាក់បំពេញនូវរឿងរ៉ាវលើជញ្ជាំងប្រាសាទអង្គរវត្ត។







*ជញ្ជាំងពីរផ្ទាំងធំៗនៅមុមធ្លៀសាននៃប្រាសាទអង្គរវត្តកាលជំនាន់ដែលសាងសង់ដំបូង (ស.វ.ទី១២) គឺពុំទាន់មានចម្លាក់អ្វីទាំងអស់។  គឺព្រះបាទអង្គច័ន្ទនេះឯងហើយ ដែលបានឱ្យគេទៅឆ្លាក់បំពេញ ពោលគឺផ្ដើមនៅគ.ស ១៥៤៦ ហើយចប់នៅគ.ស.១៥៦៤។*







*នៅរបៀងខាងកើត, ចំហៀងខាងជើង ចម្លាក់នោះនិយាយពីជ័យជំនះនៃព្រះនារាយណ៍លើពពួកអសោរ។ រីឯនៅរបៀងខាងជើង, ចំហៀងខាងកើត គឺនិយាយអំពីជ័យជំនះរបស់ព្រះក្រឹស្ណាលើ «ពាណ»។*

*បើមើលអក្សរដែលចារលើផ្ទាំងនោះតែម្ដង ទើបយល់ពីព្រះតម្រិះនៃព្រះបាទអង្គច័ន្ទ។  តាមពិតទៅពាក្យចារឹកពន្យល់ពីរកន្លែងដែលពុំសូវជាវែងប៉ុន្មាននោះ បានចោទជាបញ្ហាដល់អ្នកស្រាវជ្រាវអស់ពេលជាងពាក់កណ្ដាលសតវត្ស។  លុះមកដល់ឆ្នាំ១៩៦២ ទើបលោក* **George Coedes** *ទម្លុះទម្លាយបញ្ហានិងចម្ងល់ទាំងពួងបានជ្រះស្រលះ។  ខាងក្រោមនេះគឺការចម្លងពាក្យពេចន៍ដែលចារ មកដាក់ជាអក្សរពុម្ពយើងសព្វថ្ងៃះ*

ព្រះបាទមហាវិស្ណុលោកទ្រង់តាំងទានស្រេចនៅដែនព្យួរ លុះទ្រង់រាជព្រះបាទស្ដេចព្រះរាជឱង្ការ

បរមរាជាធិរាជរាមាធិបតិ បរមចក្រពត្តិរាជ ប្រើព្រះមហីធរ នារាជសិល្បិបុនរេខ្មដែនធិយាយ

អង្គ ... កំលុងអម្ពុសក មមិនត្រូវ ពុទ្ធារបុណ្ណាមិ ភទ្របទ

សង្ខេបនិងសម្រួលឱ្យអ្នកអានសម័យថ្មីងាយយល់មានន័យថា «ព្រះបាទ**មហាវិស្ណុលោក** (ព្រះបាទសូរ្យវរ្ម័នទី២) សាងពុំបានសព្វគ្រប់ទេ នៅសល់ពីរផ្ទាំងទៀត លុះព្រះបាទ**ព្រះរាជឱង្ការបរមរាជារាមាធិបតី** (ព្រះបាទអង្គច័ន្ទទី១) ឡើងជាព្រះរាជាមក ព្រះអង្គប្រើព្រះមហីធរ ដែលនៅក្នុងក្រុមរាជវាំងឱ្យធ្វាក់រៀបរាប់រឿង ... [ទីនេះថ្មបែកខូចអក្សរ] នៅថ្ងៃពុធ ទី៨ ខែកញ្ញា គ.ស.១៥៤៦»។

នៅរបៀងខាងជើង, ចំហៀងខាងកើត មានអក្សរចារឹកមួយទៀត៖

> ព្រះបាទមហាវិស្ណុលោកធ្វើពុំបានសំរេចនៅផ្ទាំងព្យារ ធ្វើរាជព្រះបាទសំដេចព្រះរាជឱង្ការ
> បរមរាជាធិរាជឥតបរមបពិត្រ ឲ្យធ្វាកនិយាយ ឲ្យសាសំរេចលោលុះគល់កចត្វារអម្ពបញ្ចសក
> កុម្ភិត្ត្រ ប្ញធ្មីជលុណសាអាទិត្យពារ សំរេចឲ្យរឿងភ្លាកនៃព្យារមុម បុរេថ្វើ

សង្ខេបនិងសម្រួល៖

«ព្រះបាទសូរ្យវរ្ម័នទី២ សាងពុំបានសព្វគ្រប់ទេ នៅសល់ពីរផ្ទាំងទៀត លុះលុះព្រះបាទអង្គច័ន្ទឡើងជាព្រះរាជាមក ព្រះអង្គឱ្យគេធ្វាក់រឿងនិទាន។ គេប្រឹងប្រែងធ្វាក់លុះសម្រេចចប់នៅថ្ងៃអាទិត្យ ទី២៧ ខែកុម្ភៈ គ.ស.១៥៦២ នូវរបៀងទាំងពីរដូចបុរាណកាល»។




ការធ្វាក់នេះ យើងពុំអាចដឹងថាមានផ្អាកពេលខ្លះ ហើយប្រសិនបើមាន ផ្អាកនោះប៉ុន្មានដងឡើយ គ្រាន់តែឃើញថារយៈពេលទាំងអស់គឺ១៧ឆ្នាំ។ តែប្រការដែលខ្ញុំចង់គូសសង្កត់នៅទីនេះ គឺពាក្យចុងក្រោយដែលសម្រួលថា «ដូចបុរាណកាល»។ ពាក្យដើមលើអក្សរថ្មនោះគឺ «បុរេថ្វើ» ប្រែឱ្យចំថា «ដូចព្រេង» មានន័យថាដូចពីព្រេងនាយ, គោរពតាមគំនិតពីព្រេងនាយ។

*នេះពុំនិយាយពីប្រាសាទតូចៗរាប់ពុំអស់ ដែលបានទទួលការរៀបចំផងដែរ នៅទីជិតឬឆ្ងាយពីអង្គរ ក៏ការរៀបចំកសាងបុរាណដ្ឋានចេះតែមានជាហូរហែក្នុងរាជ្យបន្ទាប់ៗមកទៀត នៅស.វ.ទី១៦។*

កំណត់របស់ *Khmer Story Lovers* ៖ ថ្វីបើនៅសតវត្សទី១៦ខ្មែរបានកាន់ព្រះពុទ្ធសាសនាថេរវាទ (ឬនិកាយហិនយាន) យ៉ាងខ្ជាប់ខ្ជួនទៅហើយ  ប៉ុន្តែរឿងរាមកេរ្តិ៍ ដែលជារឿងបែបព្រហ្មញ្ញសាសនា នៅតែមានប្រជាប្រិយភាពក្នុងស្រទាប់មហាជនខ្មែរ  ហើយតួអង្គព្រះរាមត្រូវបានបម្លែងឱ្យទៅជាតួព្រះពោធិសត្វតាមបែបព្រះពុទ្ធសាសនាទៀតផង។  តាមព្ទចាស់ៗដំណាល ថារឿងរាមកេរ្តិ៍ត្រូវបានព្រះសង្ឃនៅតាមវត្តអារាមទូទាំងប្រទេសខ្មែរ លើកមកនិទានពេលទេសនា រហូតដល់កំឡុងឆ្នាំ ១៩៥០ - ១៩៦០ ទើបមានការបញ្ជាក់ពីសម្តេចសង្ឃថារឿងនោះជារឿងបែបព្រហ្មញ្ញសាសនាទេ ទើបព្រះសង្ឃខ្មែរឈប់ទេសរឿងរាមកេរ្តិ៍ទៀត។  ដូច្នេះការដែលព្រះបាទច័ន្ទរាជាត្រាស់បង្គាប់ឱ្យគេឆ្លាក់បន្តនូវរឿងរ៉ាវបែបព្រហ្មញ្ញសាសនា លើជញ្ជាំងប្រាសាទអង្គរវត្ត ប្រហែលពុំមែនជារឿងចម្លែកណាស់ណាទេ  ប៉ុន្តែខ្ញុំយល់ស្របតាមយោបល់របស់លោក **អាំង ជូលាន** ដែលកោតស្ញប់ស្ញែងដល់បុព្វបុរសនៅសតវត្សទី១៦ គឺបង្ហាញថាពួកគាត់មានសេចក្តីគោរពចំពោះបុព្វបុរសជាន់មុន ថ្វីបើមានការកសាងស្នាដៃថ្មី ក៏នៅតែគោរពរក្សាមរតកពីបុរាណកាល  ពុំលុបបំបាត់ កែប្រែ ជាន់ឈ្លីស្នាដៃមនុស្សជាន់មុន ហើយអួតក្អេងក្អាង លើកតម្កើងស្នាដៃខ្លួនថាអស្ចារ្យគ្មានគេប្រៀប។  ខ្ញុំគោរពកោតសរសើរដល់ស្នាដៃចម្លាក់នៃស.វ.ទី១៦ ថ្វីបើទឹកដៃនិងប្រណីតភាពនៃចម្លាក់ទាំងនោះ ពុំសូវស្អាងស្អាត ល្អវិចិត្រដូចចម្លាក់ស.វ.ទី១២ក៏ដោយចុះ  ក៏ជាការបង្ហាញនូវការព្យាយាមនិងបំណងល្អក្នុងការបង្រួបចន្លោះខ្វះខាតដែលបន្សល់មកពីជំនាន់មុន។




